ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៦ ១៣. ០០៨ ធ.ស.៣

## សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី២ របស់ធនាគារជាតិនៃកម្ពុជាស្តីពី
## ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

កម្រិតដុល្លារូបនីយកម្មបានកើនឡើងនៅកម្ពុជាក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយ ដោយកម្រិតប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសធៀបនឹងរូបិយវត្ថុទូទៅបានកើនឡើងពី ៦០% ក្នុងទសវត្សរ៍ ឆ្នាំ១៩៩០ ដល់ ៨០% ក្នុងទសវត្សរ៍ឆ្នាំ២០០០ និងបច្ចុប្បន្នមានកម្រិត ៨៣% ។ ដុល្លារូបនីយកម្មមានទាំងគុណសម្បត្តិនិងគុណវិបត្តិចំពោះកម្ពុជា ។ ចំពោះគុណសម្បត្តិ ដុល្លារូបនីយកម្មបានរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ពង្រឹងជំនឿទុកចិត្តសាធារណជននៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍប្រទេស ។ ដុល្លារូបនីយកម្មក៏បានបង្កើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងអន្តរការិយកម្មហិរញ្ញវត្ថុជាលំដាប់ ។ ទន្ទឹមនេះ ដុល្លារូបនីយកម្មក៏នាំមកនូវការខាតបង់ប្រាក់ចំណូលដែលទទួលបានពីការបោះពុម្ពរូបិយវត្ថុជាតិ និងដាក់កំហិតលើតួនាទីជាអ្នកឱ្យខ្ចីចុងក្រោយរបស់ធនាគារជាតិនៃកម្ពុជា ។ លើសពីនេះ ការប្រើប្រាស់ប្រាក់ដុល្លារបានធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងអាចបង្កជាហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ ជាពិសេសគឺហានិភ័យសន្ទនីយភាព ។

នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាការងារអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ។ រហូតមកដល់បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត បានគាំទ្រនិងរួមចំណែកក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ។ ជាលទ្ធផល នៅក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ ប្រាក់រៀលក្នុងចរាចរណ៍ និងប្រាក់បញ្ញើជារៀលបានកើនឡើងជាមធ្យម ១៧% និង ២៤% រៀងគ្នាក្នុងមួយឆ្នាំ ។ ដើម្បីជំរុញវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងរៀបចំយុទ្ធសាស្ត្រជាតិមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិដោយផ្អែកលើយន្តការទីផ្សារ ហើយការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ជាពិសេស ទីផ្សារប្តូរប្រាក់ ទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ និងទីផ្សារមូលបត្រ មានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការគាំទ្រចំពោះការអនុវត្តនេះ ។

ទោះបីជាភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុក្នុងរយៈពេល ២ ទសវត្សរ៍កន្លងមកមានភាពល្អប្រសើរក៏ដោយ ក៏ទីផ្សារហិរញ្ញវត្ថុមួយចំនួនស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ ។ ទីផ្សារប្តូរប្រាក់មានលក្ខណៈដាច់ដោយផ្នែកៗនៅឡើយ ដោយអាជីវករប្តូរប្រាក់ដើរតួនាទីចម្បងជាអ្នកទិញ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ផង ជាឈ្មួញកណ្តាលផង និងជាអ្នកកំណត់តម្លៃផង ថ្វីបើគ្រឹះស្ថានធនាគារបានចូលរួមកាន់តែសកម្ម នៅក្នុងទីផ្សារប្តូរប្រាក់ ។ ធនាគារជាតិនៃកម្ពុជាបានគាំទ្រការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCDs) ។ ទោះយ៉ាងណា ទីផ្សារមូលបត្ររដ្ឋ និង ទីផ្សារបន្ទាប់សម្រាប់ NCDs នៅមិនទាន់បានអភិវឌ្ឍនៅឡើយ ហើយទីផ្សារមូលបត្រនៅកម្ពុជា ទើបតែបានចាប់ដំណើរការ នៅឆ្នាំ២០១២ ដោយមានក្រុមហ៊ុនចំនួន ២ បានចុះបញ្ជី ។

ដើម្បីកំណត់គោលនយោបាយនិងវិធានការដែលសមស្រប សម្រាប់លើកកម្ពស់ការប្រើប្រាស់ ប្រាក់រៀល ធនាគារជាតិនៃកម្ពុជាមានក្តីសោមនស្សរីករាយ ប្រកាសជូននូវប្រធានបទនៃសន្និសីទ ម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ ស្តីពី **ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុដើម្បីរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល** ។

ធនាគារជាតិនៃកម្ពុជាលើកទឹកចិត្តឱ្យអ្នកស្រាវជ្រាវទាំងឡាយធ្វើការស្រាវជ្រាវពាក់ព័ន្ធនឹង ប្រធានបទខាងលើ ដែលលទ្ធផលនៃការស្រាវជ្រាវនឹងអាចរួមចំណែកក្នុងការបង្កើតគោលនយោបាយ ដើម្បីឈានទៅសម្រេចគោលដៅបង្កើនការប្រើប្រាស់ប្រាក់រៀល ។ ដើម្បីសម្រេចបានតាមគោល បំណងនេះ ធនាគារជាតិនៃកម្ពុជាស្វាគមន៍ចំពោះអត្ថបទស្រាវជ្រាវដែលផ្តោតទៅលើ ៖ ១) ការលើក កម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមរយៈការអភិវឌ្ឍទីផ្សារប្តូរប្រាក់ ២) ការលើកកម្ពស់ការប្រើប្រាស់ ប្រាក់រៀលតាមរយៈការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ ៣) ការលើកកម្ពស់ការប្រើប្រាស់ប្រាក់ រៀលតាមរយៈការអភិវឌ្ឍទីផ្សារមូលបត្រ ។ល។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏លើកទឹកចិត្តឱ្យ អ្នកស្រាវជ្រាវទាំងឡាយមានគំនិតច្នៃប្រឌិត និងកំណត់ប្រធានបទផ្ទាល់របស់ខ្លួនទាំងឡាយណាដែល ពាក់ព័ន្ធនឹងប្រធានបទនៃសន្និសីទនេះផងដែរ ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រធានបទនិងប្រវត្តិរូបសង្ខេបមកធនាគារជាតិនៃ កម្ពុជាឲ្យបានត្រឹមថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ។ អត្ថបទស្រាវជ្រាវចំនួន ៤ ឬ ៥ នឹងត្រូវជ្រើសរើស ហើយលទ្ធផលនៃការជ្រើសរើសនេះនឹងប្រកាសជូនក្នុងសប្តាហ៍ទី២ ខែមីនា ឆ្នាំ២០១៥ ។ សូមបញ្ជាក់ថា ក្នុងចំណោមអត្ថបទស្រាវជ្រាវដែលត្រូវបានជ្រើសរើស មានតែអត្ថបទដែលមានគុណភាពសមស្រប ប៉ុណ្ណោះ នឹងត្រូវអនុញ្ញាតឱ្យធ្វើបទបង្ហាញក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី២ របស់ធនាគារ ជាតិនៃកម្ពុជា ដែលគ្រោងនឹងរៀបចំឡើងនៅចុងខែមិថុនា ឆ្នាំ២០១៥ ។ ធនាគារជាតិនៃកម្ពុជា នឹង ផ្តល់ជូនរង្វាន់លើកទឹកចិត្តចំពោះអត្ថបទស្រាវជ្រាវ ដែលនឹងត្រូវជ្រើសរើសមកធ្វើបទបង្ហាញនេះ ។

**សូមទំនាក់ទំនងមកកាន់ ៖**

ធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
Tel: ០៩៧ ៩៧ ១១១១៤
Email: vouthy.khou@nbc.org.kh